# របាយការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលថ្នាក់ជាតិ

# ប្រចាំខែមិថុនា ឆ្នាំ ២០២០

*(ទិន្នន័យបឋម)*

**មាតិកា** **ទំព័រ**


១.សេចក្តីសង្ខេប ១

២.តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

២.១.តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល ២

២.២.តារាងស្ថិតិចំណូល ៣

២.៣.តារាងស្ថិតិចំណាយ ៥

២.៤.តារាងស្ថិតិប្រតិបត្តិការទ្រព្យសកម្ម និងបំណុល ៦

២.៥.តារាងស្ថិតិពីភាពខុសគ្នានៃស្ថិតិ TOFE និងស្ថិតិ GFS ៧

៣.ក្រាហ្វិក ៨

៤.ឧបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលទូទៅ ១០

៥.ឧបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិ ១១

៦.សេចក្តីសង្ខេបអំពី "ក្របខ័ណ្ឌប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល" ១២


Reference: Government Finance Statistics Manual 2014 (GFSM 2014)

## ១.សេចក្តីសង្ខេប
## ស្តីពីការអនុវត្តថវិកា ខែមិថុនា ឆ្នាំ២០២០

(១).**ការអនុវត្តចំណូល÷** ក្នុងខែមិថុនា ឆ្នាំ២០២០ ចំណូលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន **១ ៤៩៩ ៣៧៤** លានរៀល មានកំណើនអវិជ្ជមានក្នុងរង្វង់ **៣៣,៤0%** ឬស្មើនឹង **៧៥១ ៧៨0** លានរៀល បើធៀបនឹងខែមិថុនា ឆ្នាំ២០១៩ ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ ចំណូលរដ្ឋបាលថ្នាក់ជាតិសរុបអនុវត្តបាន **១១ ៤៧១ ៥៤៦** លានរៀល ឬស្មើនឹង **៤៦,១៣%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ឬមានកំណើនអវិជ្ជមានប្រមាណ **៦,២៦%** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៩ ដែលក្នុងនោះមានចំណូលពន្ធ **៨៥,២៩%,** ចំណូលផ្សេងៗ **៤,២៦%** និងចំណូលពីអំណោយ **១0,៤៥%** ។

(២).**ចំណាយសរុប÷** ក្នុងខែមិថុនា ឆ្នាំ២០២០ ចំណាយសរុបរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន **២ ៥៤១ ៧៤៣** លានរៀល គឺបានកើនឡើងប្រមាណ **២៦,៦៧%** ឬស្មើនឹង **៥៣៥ ១៨៩** លានរៀល បើធៀបទៅនឹងខែមិថុនា ឆ្នាំ២០១៩ ដែលក្នុងនោះ ចំណាយ (ចរន្ត) អនុវត្តបាន **១ ៤៨១ ២១៨** លានរៀល និងទ្រព្យមិនមែនហិរញ្ញវត្ថុ (មូលធន) អនុវត្តបាន **១ 0៦0 ៥២៥** លានរៀល ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ ចំណាយសរុបអនុវត្តបាន **១១ 0៥៩ ៨៧២** លានរៀល ឬស្មើនឹង **៣៨,៥៣%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ឬបានកើនឡើង **១៦,៩៧%** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩ ។ ចំណាយសរុបនេះរួមមាន**ចំណាយ** (expense) សម្រេចបាន **៤៦,១២%** និង**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ** (net acquisition of non-financial assets) សម្រេចបាន **២៧,៩៥%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ។

(៣).**តុល្យភាពប្រតិបត្តិការដុល** (ចំណូលដកចំណាយ)÷ គិតត្រឹមខែឆមាសទី១ ឆ្នាំ២០២០ តុល្យភាពប្រតិបត្តិការដុលមានសមតុល្យចំនួន **៣ ៧៦២ ៣២៥** លានរៀល ឬបានថយចុះ **៣៣,៧១%** បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៩ ។ ចំណែកឯ **សមតុល្យនៃការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ** (ចំណូលដកចំណាយសរុប) គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ នេះមានសមតុល្យសរុប **៤១១ ៦៧៤** លានរៀល ដែលក្នុងនោះមានទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធសរុបចំនួន **១ ១៤៣ ៥0៤** លានរៀល និងបំណុលសរុបមានចំនួន **៧៣៣ ៥៧៩** លានរៀល ។

(៤).**សន្និដ្ឋាន÷** ផ្អែកលើទិន្នន័យបឋមនៃការអនុវត្តក្នុងឆមាសទី១ នៃឆ្នាំ២០២០ ការអនុវត្តចំណូលថវិកាសរុបរបស់រដ្ឋបាលថ្នាក់ជាតិមានកំណើនអវិជ្ជមាន **(-៦,២៦%)** ធៀបនឹងឆ្នាំ២០១៩ ស្របពេលដែលការអនុវត្តចំណាយសរុបមានកំណើនវិជ្ជមាន **(១៦,៩៧%)** ។ បើទោះបីជាសេដ្ឋកិច្ចកម្ពុជាជារួមបានរងផលប៉ះពាល់ដោយផ្ទាល់ និង/ឬដោយប្រយោលពីជំងឺកូវីដ-១៩ ពិតមែន តែគិតត្រឹមឆមាសទី១ ឆ្នាំ២០២០ ការអនុវត្តចំណូលនិងចំណាយសរុបនៅតែឆ្លុះបញ្ចាំងនូវនិន្នាការមួយអាចគ្រប់គ្រងបាន ដោយសមតុល្យនៃការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ (Net Lending/Net Borrowing) រក្សាបានអតិរេកសរុប **៤១១ ៦៧៤** លានរៀល (វិជ្ជមាន) ។ ទោះជាយ៉ាងណាក្តី ការផ្ទុះឡើង នៃជំងឺកូវីដ-១៩ នឹងផ្តល់ផលប៉ះពាល់ដល់ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ជាតិក្នុងឆ្នាំ២០២០ នេះ ។

ឯកតា÷ លានរៀល

# តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

## ២.១. ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

| | | ច្បាប់ឆ្នាំ ២០២០ | អនុវត្តន៍ ២០២០ | អនុ/ច្បា ២០២០ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **24,869,592.0** | **11,471,545.9** | **46.13%** | **1,762,281.9** | **1,945,526.5** | **2,034,851.9** | **2,684,911.7** | **1,544,600.1** | **1,499,373.8** | **...** | **...** | **...** | **...** | **...** | **...** |
| 11 | ពន្ធ | 20,793,145.0 | 9,783,732.0 | 47.05% | 1,474,044.1 | 1,437,951.4 | 1,727,606.8 | 2,493,912.0 | 1,341,347.4 | 1,308,870.3 | ... | ... | ... | ... | ... | ... |
| 13 | អំណោយ | 1,250,277.0 | 488,487.9 | 39.07% | 79,856.4 | 79,856.4 | 79,856.4 | 89,205.9 | 79,856.4 | 79,856.4 | ... | ... | ... | ... | ... | ... |
| 14 | ចំណូលផ្សេងៗ | 2,826,170.0 | 1,199,326.0 | 42.44% | 208,381.4 | 427,718.7 | 227,388.7 | 101,793.9 | 123,396.3 | 110,647.1 | ... | ... | ... | ... | ... | ... |
| **2** | **ចំណាយ** | **16,714,297.8** | **7,709,220.9** | **46.12%** | **717,332.7** | **1,562,144.8** | **1,463,777.4** | **1,440,583.3** | **1,044,165.0** | **1,481,217.8** | **...** | **...** | **...** | **...** | **...** | **...** |
| 21 | បន្ទុកបុគ្គលិក | 8,337,283.9 | 3,824,555.8 | 45.87% | 537,380.9 | 629,397.1 | 779,225.4 | 531,235.9 | 621,956.0 | 725,360.5 | ... | ... | ... | ... | ... | ... |
| 22 | ទំនិញ និងសេវាកម្ម | 3,390,043.3 | 816,294.8 | 24.08% | 10,864.3 | 123,533.5 | 120,121.9 | 246,414.8 | 175,261.3 | 140,099.0 | ... | ... | ... | ... | ... | ... |
| 24 | ការប្រាក់ | 542,077.0 | 166,073.6 | 30.64% | 6,526.8 | 101,803.7 | 37,188.0 | 12,582.6 | 6,250.4 | 1,722.1 | ... | ... | ... | ... | ... | ... |
| 25 | ឧបត្ថម្ភធន | 11,000.0 | 205,000.0 | 1863.64% | 0.0 | 0.0 | 0.0 | 205,000.0 | 0.0 | 0.0 | ... | ... | ... | ... | ... | ... |
| 26 | អំណោយ | 1,602,082.7 | 1,282,138.5 | 80.03% | 58,779.0 | 443,029.1 | 288,806.4 | 105,586.5 | 35,034.7 | 350,902.9 | ... | ... | ... | ... | ... | ... |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 1,811,692.4 | 849,558.9 | 46.89% | 90,003.2 | 93,390.8 | 125,351.5 | 274,137.4 | 146,037.4 | 120,638.5 | ... | ... | ... | ... | ... | ... |
| 28 | ចំណាយផ្សេងៗ | 1,020,118.5 | 565,599.3 | 55.44% | 13,778.5 | 170,990.7 | 113,084.3 | 65,625.9 | 59,625.2 | 142,494.7 | ... | ... | ... | ... | ... | ... |
| ***GOB*** | ***តុល្យភាពប្រតិបត្តិការដុល*** | **8,155,294.2** | **3,762,325.0** | **46.13%** | **1,044,949.2** | **383,381.7** | **571,074.5** | **1,244,328.4** | **500,435.1** | **18,156.0** | **...** | **...** | **...** | **...** | **...** | **...** |
| ***NOB*** | ***តុល្យភាពប្រតិបត្តិការសុទ្ធ*** | **8,155,294.2** | **3,762,325.0** | **46.13%** | **1,044,949.2** | **383,381.7** | **571,074.5** | **1,244,328.4** | **500,435.1** | **18,156.0** | **...** | **...** | **...** | **...** | **...** | **...** |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | 11,987,442.2 | 3,350,651.2 | 27.95% | 372,891.8 | 384,829.3 | 634,724.4 | 559,289.4 | 338,391.4 | 1,060,524.9 | ... | ... | ... | ... | ... | ... |
| 311 | ទ្រព្យអចលត៍ | 11,987,442.2 | 3,350,651.2 | 27.95% | 372,891.8 | 384,829.3 | 634,724.4 | 559,289.4 | 338,391.4 | 1,060,524.9 | ... | ... | ... | ... | ... | ... |
| ***2M*** | ***ចំណាយសរុប*** | 28,701,740.0 | 11,059,872.1 | 38.53% | 1,090,224.5 | 1,946,974.1 | 2,098,501.8 | 1,999,872.6 | 1,382,556.3 | 2,541,742.7 | ... | ... | ... | ... | ... | ... |
| ***NLB*** | ***សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី*** | **-3,832,148.0** | **411,673.8** | **...** | **672,057.5** | **-1,447.6** | **-63,649.9** | **685,039.0** | **162,043.8** | **-1,042,368.9** | **...** | **...** | **...** | **...** | **...** | **...** |
| **32** | **ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | 244,843.0 | 1,143,503.9 | 467.04% | 794,917.0 | -66,521.4 | 41,640.1 | 997,967.8 | 265,667.5 | -890,167.0 | ... | ... | ... | ... | ... | ... |
| 321 | ក្នុងប្រទេស | 244,843.0 | 1,143,503.9 | 467.04% | 794,917.0 | -66,521.4 | 41,640.1 | 997,967.8 | 265,667.5 | -890,167.0 | ... | ... | ... | ... | ... | ... |
| **33** | **បំណុលសុទ្ធ** | 4,076,991.0 | 733,578.9 | 17.99% | 122,859.5 | -63,447.8 | 105,290.0 | 313,051.6 | 103,623.8 | 152,201.9 | ... | ... | ... | ... | ... | ... |
| 332 | ក្រៅប្រទេស | 4,076,991.0 | 733,578.9 | 17.99% | 122,859.5 | -63,447.8 | 105,290.0 | 313,051.6 | 103,623.8 | 152,201.9 | ... | ... | ... | ... | ... | ... |

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០
**អគ្គនាយក**
**អគ្គនាយកដ្ឋានគោលនយោបាយ**

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០
**ប្រធាននាយកដ្ឋាន**
**នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច**

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០
**ប្រធានការិយាល័យ**
**ការិយាល័យស្ថិតិហិរញ្ញវត្ថុសាធារណៈ**

# តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

ឯកតា÷ លានរៀល

## ២.២.តារាងស្ថិតិចំណូល

| | | ច្បាប់ឆ្នាំ ២០២០ | អនុវត្តន៍ ២០២០ | អនុ/ច្ប ២០២០ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **24,869,592.0** | **11,471,545.9** | **46.13%** | **1,762,281.9** | **1,945,526.5** | **2,034,851.9** | **2,684,911.7** | **1,544,600.1** | **1,499,373.8** | **...** | **...** | **...** | **...** | **...** | **...** |
| **11** | **ពន្ធ** | **20,793,145.0** | **9,783,732.0** | **47.05%** | **1,474,044.1** | **1,437,951.4** | **1,727,606.8** | **2,493,912.0** | **1,341,347.4** | **1,308,870.3** | **...** | **...** | **...** | **...** | **...** | **...** |
| **111** | **ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណេញ** | 5,080,000.0 | 3,319,403.6 | 65.34% | 259,121.3 | 203,490.1 | 447,385.4 | 1,634,106.6 | 466,216.2 | 309,083.9 | ... | ... | ... | ... | ... | ... |
| 1111 | ពន្ធរូបវន្តបុគ្គល | 1,080,000.0 | 482,933.9 | 44.72% | 76,836.6 | 62,773.7 | 116,041.2 | 90,394.2 | 61,563.9 | 75,324.4 | ... | ... | ... | ... | ... | ... |
| 1112 | ពន្ធនីតិបុគ្គល | 4,000,000.0 | 2,836,469.7 | 70.91% | 182,284.7 | 140,716.5 | 331,344.3 | 1,543,712.4 | 404,652.3 | 233,759.5 | ... | ... | ... | ... | ... | ... |
| **114** | **ពន្ធលើទំនិញ និងសេវាប្រើប្រាស់** | 12,956,745.0 | 5,402,036.2 | 41.69% | 1,005,128.2 | 1,045,911.5 | 1,062,238.1 | 721,644.9 | 723,789.5 | 843,323.9 | ... | ... | ... | ... | ... | ... |
| 1141 | ពន្ធទូទៅលើទំនិញ និងសេវាប្រើប្រាស់ | 7,222,800.0 | 3,045,777.5 | 42.17% | 506,478.9 | 579,969.2 | 623,733.1 | 421,529.9 | 396,338.6 | 517,727.8 | ... | ... | ... | ... | ... | ... |
| 11411 | អាករលើតម្លៃបន្ថែម | 7,222,800.0 | 3,045,775.5 | 42.17% | 506,476.8 | 579,969.2 | 623,733.1 | 421,529.9 | 396,338.6 | 517,727.8 | ... | ... | ... | ... | ... | ... |
| 11413 | ពន្ធលើផលរបរ និងពន្ធលើទំនិញ និងសេវាកម្មផ្សេងៗ | 0.0 | 2.0 | … | 2.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... | ... | ... |
| 1142 | អាករពិសេស | 5,733,945.0 | 2,356,258.7 | 41.09% | 498,649.3 | 465,942.4 | 438,505.0 | 300,115.0 | 327,450.9 | 325,596.0 | ... | ... | ... | ... | ... | ... |
| **115** | **ពន្ធលើពាណិជ្ជកម្មអន្តរជាតិ** | 2,756,400.0 | 1,062,292.2 | 38.54% | 209,794.6 | 188,549.8 | 217,983.3 | 138,160.4 | 151,341.6 | 156,462.5 | ... | ... | ... | ... | ... | ... |
| 1151 | អាករ និងបន្ទុកនាំចូលផ្សេងៗ | 2,707,300.0 | 1,053,384.3 | 38.91% | 207,516.1 | 186,264.4 | 216,153.9 | 137,780.9 | 150,759.9 | 154,909.1 | ... | ... | ... | ... | ... | ... |
| 1152 | ពន្ធនាំចេញ | 49,100.0 | 8,907.8 | 18.14% | 2,278.5 | 2,285.3 | 1,829.4 | 379.4 | 581.7 | 1,553.4 | ... | ... | ... | ... | ... | ... |
| **13** | **អំណោយ** | **1,250,277.0** | **488,487.9** | **39.07%** | **79,856.4** | **79,856.4** | **79,856.4** | **89,205.9** | **79,856.4** | **79,856.4** | **...** | **...** | **...** | **...** | **...** | **...** |
| **131** | **អំណោយពីរដ្ឋាភិបាលអន្តរជាតិ** | 579,483.0 | 153,090.9 | 26.42% | 23,956.9 | 23,956.9 | 23,956.9 | 33,306.4 | 23,956.9 | 23,956.9 | ... | ... | ... | ... | ... | ... |
| 1311 | ចរន្ត | 130,000.0 | … | … | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... | ... | ... |
| 1312 | មូលធន | 449,483.0 | 153,090.9 | 34.06% | 23,956.9 | 23,956.9 | 23,956.9 | 33,306.4 | 23,956.9 | 23,956.9 | ... | ... | ... | ... | ... | ... |
| **132** | **អំណោយពីអង្គការអន្តរជាតិ** | 670,794.0 | 335,397.0 | 50.00% | 55,899.5 | 55,899.5 | 55,899.5 | 55,899.5 | 55,899.5 | 55,899.5 | ... | ... | ... | ... | ... | ... |
| 1322 | មូលធន | 670,794.0 | 335,397.0 | 50.00% | 55,899.5 | 55,899.5 | 55,899.5 | 55,899.5 | 55,899.5 | 55,899.5 | ... | ... | ... | ... | ... | ... |
| **14** | **ចំណូលផ្សេងៗ** | **2,826,170.0** | **1,199,326.0** | **42.44%** | **208,381.4** | **427,718.7** | **227,388.7** | **101,793.9** | **123,396.3** | **110,647.1** | **...** | **...** | **...** | **...** | **...** | **...** |
| **141** | **ចំណូលពីទ្រព្យសម្បត្តិ** | 384,669.0 | 390,844.9 | 101.61% | 19,842.0 | 284,003.7 | 21,484.8 | 24,808.4 | 20,548.2 | 20,157.9 | ... | ... | ... | ... | ... | ... |
| 1411 | ចំណូលការប្រាក់ | 146,926.0 | 52,085.7 | 35.45% | 0.0 | 11,512.2 | 13,896.4 | 13,627.5 | 1,203.7 | 11,845.9 | ... | ... | ... | ... | ... | ... |
| 14112 | ចំណូលការប្រាក់ក្នុងប្រទេស | 146,926.0 | 52,085.7 | 35.45% | 0.0 | 11,512.2 | 13,896.4 | 13,627.5 | 1,203.7 | 11,845.9 | ... | ... | ... | ... | ... | ... |
| 1412 | ចំណូលភាគលាភ | 19,650.0 | 272,388.6 | 1386.20% | 6,884.8 | 263,105.7 | 0.0 | 320.0 | 2,078.1 | 0.0 | ... | ... | ... | ... | ... | ... |
| 1413 | ចំណូលផលទុននៃសេវាផ្គត់ផ្គង់ (អគ្គិសនី, ទឹក...) | 0.0 | 35.9 | … | 0.0 | 0.0 | 0.0 | 18.8 | 0.0 | 17.1 | ... | ... | ... | ... | ... | ... |
| 1415 | ចំណូលពីការជួល | 218,093.0 | 66,334.7 | 30.42% | 12,957.2 | 9,385.9 | 7,588.3 | 10,842.1 | 17,266.3 | 8,294.9 | ... | ... | ... | ... | ... | ... |

# តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

ឯកតា÷ លានរៀល

## ២.២.តារាងស្ថិតិចំណូល

| | | ច្បាប់ឆ្នាំ ២០២០ | អនុវត្តន៍ ២០២០ | អនុ/ច្ប ២០២០ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **142** | **ចំណូលពីការលក់ទំនិញ និងសេវាកម្ម** | 2,258,055.2 | 716,285.9 | 31.72% | 179,517.6 | 132,163.6 | 182,765.2 | 60,985.7 | 88,151.8 | 72,701.9 | ... | ... | ... | ... | ... | ... |
| 1421 | ចំណូលពីការលក់ក្នុងទីផ្សារ | 574,330.3 | 299,999.8 | 52.23% | 87,357.1 | 22,582.8 | 87,234.5 | 23,251.5 | 32,033.6 | 47,540.3 | ... | ... | ... | ... | ... | ... |
| 1422 | ចំណូលសេវារដ្ឋបាល | 1,139,210.7 | 330,371.3 | 29.00% | 50,411.0 | 81,034.2 | 84,486.4 | 37,422.8 | 53,478.6 | 23,538.4 | ... | ... | ... | ... | ... | ... |
| 1423 | ចំណូលពីការលក់ ឬសកម្មភាពផ្សេងៗ(ទេសចរណ៍, វប្បធម៌...) | 544,514.2 | 85,914.9 | 15.78% | 41,749.6 | 28,546.7 | 11,044.3 | 311.5 | 2,639.6 | 1,623.3 | ... | ... | ... | ... | ... | ... |
| **143** | **ចំណូលបានពីការពិន័យ** | 181,445.8 | 91,450.3 | 50.40% | 8,895.2 | 11,478.9 | 23,040.7 | 15,905.0 | 14,609.8 | 17,520.7 | ... | ... | ... | ... | ... | ... |
| **144** | **ការផ្ទេរផ្សេងៗដែលមិនបានញែក** | 2,000.0 | 744.8 | 37.24% | 126.5 | 72.4 | 98.0 | 94.8 | 86.6 | 266.6 | ... | ... | ... | ... | ... | ... |
| 1441 | ចរន្ត | 2,000.0 | 744.8 | 37.24% | 126.5 | 72.4 | 98.0 | 94.8 | 86.6 | 266.6 | ... | ... | ... | ... | ... | ... |
| 14412 | ផ្សេងៗ | 2,000.0 | 744.8 | 37.24% | 126.5 | 72.4 | 98.0 | 94.8 | 86.6 | 266.6 | ... | ... | ... | ... | ... | ... |

# តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

ឯកតា÷ លានរៀល

## ២.៣.តារាងស្ថិតិចំណាយ

| | | ច្បាប់ឆ្នាំ ២០២០ | អនុវត្តន៍ ២០២០ | អនុ/ច្ប ២០២០ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **2** | **ចំណាយ** | **16,714,297.8** | **7,709,220.9** | **46.12%** | **717,332.7** | **1,562,144.8** | **1,463,777.4** | **1,440,583.3** | **1,044,165.0** | **1,481,217.8** | **...** | **...** | **...** | **...** | **...** | **...** |
| **21** | **បន្ទុកបុគ្គលិក** | **7,731,219.9** | **3,824,555.8** | **49.47%** | **537,380.9** | **629,397.1** | **779,225.4** | **531,235.9** | **621,956.0** | **725,360.5** | **...** | **...** | **...** | **...** | **...** | **...** |
| **211** | ប្រាក់ខែ | 7,731,219.9 | 3,824,555.8 | 49.47% | 537,380.9 | 629,397.1 | 779,225.4 | 531,235.9 | 621,956.0 | 725,360.5 | ... | ... | ... | ... | ... | ... |
| **22** | **ទំនិញ និងសេវាកម្ម** | **3,156,676.8** | **816,294.8** | **25.86%** | **10,864.3** | **123,533.5** | **120,121.9** | **246,414.8** | **175,261.3** | **140,099.0** | **...** | **...** | **...** | **...** | **...** | **...** |
| **24** | **ការប្រាក់** | **525,089.0** | **166,073.6** | **31.63%** | **6,526.8** | **101,803.7** | **37,188.0** | **12,582.6** | **6,250.4** | **1,722.1** | **...** | **...** | **...** | **...** | **...** | **...** |
| **241** | បំណុលក្រៅប្រទេស | 525,089.0 | 165,879.3 | 31.59% | 6,526.8 | 101,680.5 | 37,188.0 | 12,582.6 | 6,250.4 | 1,650.9 | ... | ... | ... | ... | ... | ... |
| **25** | **ការឧបត្ថម្ភធន** | **11,000.0** | **205,000.0** | **1863.64%** | **0.0** | **0.0** | **0.0** | **205,000.0** | **0.0** | **0.0** | **...** | **...** | **...** | **...** | **...** | **...** |
| **251** | សហគ្រាសសាធារណៈ | 11,000.0 | 205,000.0 | 1863.64% | 0.0 | 0.0 | 0.0 | 205,000.0 | 0.0 | 0.0 | ... | ... | ... | ... | ... | ... |
| **26** | **អំណោយ** | **1,296,571.8** | **1,282,138.5** | **98.89%** | **58,779.0** | **443,029.1** | **288,806.4** | **105,586.5** | **35,034.7** | **350,902.9** | **...** | **...** | **...** | **...** | **...** | **...** |
| **262** | អង្គការអន្តរជាតិ | 166,837.2 | 39,669.1 | 23.78% | 0.0 | 4,867.8 | 9,210.1 | 13,795.7 | 1,927.9 | 9,867.4 | ... | ... | ... | ... | ... | ... |
| 2621 | ចរន្ត | 166,837.2 | 39,669.1 | 23.78% | 0.0 | 4,867.8 | 9,210.1 | 13,795.7 | 1,927.9 | 9,867.4 | ... | ... | ... | ... | ... | ... |
| **263** | រដ្ឋាភិបាលដទៃទៀត (រដ្ឋបាលថ្នាក់ក្រោមជាតិ,...) | 1,129,734.6 | 1,242,469.5 | 109.98% | 58,779.0 | 438,161.3 | 279,596.2 | 91,790.8 | 33,106.7 | 341,035.5 | ... | ... | ... | ... | ... | ... |
| 2631 | ចរន្ត | 1,129,734.6 | 1,242,469.5 | 109.98% | 58,779.0 | 438,161.3 | 279,596.2 | 91,790.8 | 33,106.7 | 341,035.5 | ... | ... | ... | ... | ... | ... |
| **27** | **ឧបត្ថម្ភសង្គមកិច្ច** | **1,596,371.5** | **849,558.9** | **53.22%** | **90,003.2** | **93,390.8** | **125,351.5** | **274,137.4** | **146,037.4** | **120,638.5** | **...** | **...** | **...** | **...** | **...** | **...** |
| **271** | អត្ថប្រយោជន៍សន្តិសុខសង្គម | 868,871.0 | 530,079.6 | 61.01% | 75,402.8 | 79,582.0 | 88,298.1 | 101,857.9 | 91,491.8 | 93,447.0 | ... | ... | ... | ... | ... | ... |
| **272** | អត្ថប្រយោជន៍ជំនួយសង្គម | 511,101.9 | 208,705.8 | 40.83% | 397.4 | 3,299.3 | 17,225.9 | 145,703.1 | 37,903.5 | 4,176.6 | ... | ... | ... | ... | ... | ... |
| **273** | អត្ថប្រយោជន៍សង្គមសម្រាប់មន្ត្រីរាជការ | 216,398.6 | 110,773.5 | 51.19% | 14,203.0 | 10,509.5 | 19,827.5 | 26,576.5 | 16,642.1 | 23,014.9 | ... | ... | ... | ... | ... | ... |
| **28** | **ចំណាយផ្សេងៗ** | **1,087,681.8** | **565,599.3** | **52.00%** | **13,778.5** | **170,990.7** | **113,084.3** | **65,625.9** | **59,625.2** | **142,494.7** | **...** | **...** | **...** | **...** | **...** | **...** |
| **282** | ការផ្ទេរផ្សេងៗដែលមិនបានបែងចែក | 1,087,681.8 | 564,870.3 | 51.93% | 13,778.5 | 170,810.5 | 113,084.3 | 65,457.3 | 59,566.1 | 142,173.7 | ... | ... | ... | ... | ... | ... |
| 2821 | ចរន្ត | 1,087,681.8 | 564,870.3 | 51.93% | 13,778.5 | 170,810.5 | 113,084.3 | 65,457.3 | 59,566.1 | 142,173.7 | ... | ... | ... | ... | ... | ... |
| **283** | បុព្វលាភធានារ៉ាប់រង, និងផ្សេងៗ | 1,756.2 | 729.0 | 41.51% | 0.0 | 180.2 | 0.0 | 168.6 | 59.2 | 321.0 | ... | ... | ... | ... | ... | ... |
| 2831 | បុព្វលាភធានារ៉ាប់រងចរន្ត | 1,756.2 | 729.0 | 41.51% | 0.0 | 180.2 | 0.0 | 168.6 | 59.2 | 321.0 | ... | ... | ... | ... | ... | ... |
| 28311 | បុព្វលាភធានារ៉ាប់រង | 1,756.2 | 729.0 | 41.51% | 0.0 | 180.2 | 0.0 | 168.6 | 59.2 | 321.0 | ... | ... | ... | ... | ... | ... |

# តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

ឯកតា÷ លានរៀល

## ២.៤.តារាងស្ថិតិប្រតិបត្តិការទ្រព្យសកម្ម និងបំណុល

| | | ច្បាប់ឆ្នាំ ២០២០ | អនុវត្តន៍ ២០២០ | អនុ/ច្ប ២០២០ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **3** | **បម្រែបម្រួលតម្លៃសុទ្ធនៃទ្រព្យកម្ម** | **8,155,294.2** | **3,760,576.2** | **46.11%** | **1,044,949.2** | **381,755.7** | **571,074.5** | **1,244,205.5** | **500,435.1** | **18,156.0** | **...** | **...** | **...** | **...** | **...** | **...** |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | **11,987,442.2** | **3,350,651.2** | **27.95%** | **372,891.8** | **384,829.3** | **634,724.4** | **559,289.4** | **338,391.4** | **1,060,524.9** | **...** | **...** | **...** | **...** | **...** | **...** |
| **311** | **អចលនទ្រព្យ** | 11,987,442.2 | 3,350,651.2 | 27.95% | 372,891.8 | 384,829.3 | 634,724.4 | 559,289.4 | 338,391.4 | 1,060,524.9 | ... | ... | ... | ... | ... | ... |
| **311A** | ***ការទិញ÷ អចលនទ្រព្យ*** | 11,987,451.2 | 3,352,400.0 | 27.97% | 372,891.8 | 386,455.3 | 634,724.4 | 559,412.2 | 338,391.4 | 1,060,524.9 | ... | ... | ... | ... | ... | ... |
| **311B** | ***ការលក់÷ អចលនទ្រព្យ*** | 9.0 | 1,748.9 | 19431.67% | 0.0 | 1,626.0 | 0.0 | 122.9 | 0.0 | 0.0 | ... | ... | ... | ... | ... | ... |
| 3111 | អាគារ និងសំណង់ផ្សេងៗ | 11,653,746.0 | 2,595,981.0 | 22.28% | 249,680.0 | 374,675.3 | 603,356.6 | 552,157.1 | 328,509.8 | 487,602.3 | ... | ... | ... | ... | ... | ... |
| 3111A | *ការទិញ÷ អាគារ និងសំណង់ផ្សេងៗ* | 11,653,749.0 | 2,597,729.9 | 22.29% | 249,680.0 | 376,301.3 | 603,356.6 | 552,280.0 | 328,509.8 | 487,602.3 | ... | ... | ... | ... | ... | ... |
| 3111B | *ការលក់÷ អាគារ និងសំណង់ផ្សេងៗ* | 3.0 | 1,748.9 | 58295.00% | 0.0 | 1,626.0 | 0.0 | 122.9 | 0.0 | 0.0 | ... | ... | ... | ... | ... | ... |
| 3112 | ម៉ាស៊ីន និងសម្ភារបរិក្ខា | 333,702.2 | 754,670.2 | 226.15% | 123,211.8 | 10,154.0 | 31,367.8 | 7,132.2 | 9,881.6 | 572,922.7 | ... | ... | ... | ... | ... | ... |
| 3112A | *ការទិញ÷ ម៉ាស៊ីន និងសម្ភារបរិក្ខា* | 333,702.2 | 754,670.2 | 226.15% | 123,211.8 | 10,154.0 | 31,367.8 | 7,132.2 | 9,881.6 | 572,922.7 | ... | ... | ... | ... | ... | ... |
| 3113 | អចលនទ្រព្យផ្សេងៗ | -6.0 | ... | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... | ... | ... |
| 3113B | *ការលក់÷ អចលនទ្រព្យផ្សេងៗ* | 6.0 | ... | ... | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | ... | ... | ... | ... | ... | ... |
| **32** | **ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ** | **244,843.0** | **1,143,503.9** | **467.04%** | **794,917.0** | **-66,521.4** | **41,640.1** | **997,967.8** | **265,667.5** | **-890,167.0** | **...** | **...** | **...** | **...** | **...** | **...** |
| 3202 | រូបិយប័ណ្ណ និងប្រាក់បញ្ញើ | 138,884.0 | 1,199,821.0 | 863.90% | 794,917.0 | -61,534.6 | 58,473.6 | 1,041,759.3 | 268,356.7 | -902,150.8 | ... | ... | ... | ... | ... | ... |
| 3204 | កម្ចី | 73,159.0 | -71,028.3 | -97.09% | 0.0 | -3,360.8 | -16,833.5 | -43,668.6 | -2,689.1 | -4,476.2 | ... | ... | ... | ... | ... | ... |
| 3205 | ដើមទុន និងមូលនិធិភាគហ៊ុន | 32,800.0 | 14,711.2 | 44.85% | 0.0 | -1,626.0 | 0.0 | -122.9 | 0.0 | 16,460.0 | ... | ... | ... | ... | ... | ... |
| **321** | **ក្នុងស្រុក** | 244,843.0 | 1,143,503.9 | 467.04% | 794,917.0 | -66,521.4 | 41,640.1 | 997,967.8 | 265,667.5 | -890,167.0 | ... | ... | ... | ... | ... | ... |
| 3212 | រូបិយប័ណ្ណ និងប្រាក់បញ្ញើ | 138,884.0 | 1,199,821.0 | 863.90% | 794,917.0 | -61,534.6 | 58,473.6 | 1,041,759.3 | 268,356.7 | -902,150.8 | ... | ... | ... | ... | ... | ... |
| 3214 | កម្ចី | 73,159.0 | -71,028.3 | -97.09% | 0.0 | -3,360.8 | -16,833.5 | -43,668.6 | -2,689.1 | -4,476.2 | ... | ... | ... | ... | ... | ... |
| 3215 | ដើមទុន និងមូលនិធិភាគហ៊ុន | 32,800.0 | 14,711.2 | 44.85% | 0.0 | -1,626.0 | 0.0 | -122.9 | 0.0 | 16,460.0 | ... | ... | ... | ... | ... | ... |
| **33** | **បំណុលសុទ្ធ** | **4,076,991.0** | **733,578.9** | **17.99%** | **122,859.5** | **-63,447.8** | **105,290.0** | **313,051.6** | **103,623.8** | **152,201.9** | **...** | **...** | **...** | **...** | **...** | **...** |
| 3304 | កម្ចី | 4,076,991.0 | 733,578.9 | 17.99% | 122,859.5 | -63,447.8 | 105,290.0 | 313,051.6 | 103,623.8 | 152,201.9 | ... | ... | ... | ... | ... | ... |
| **332** | **ក្រៅស្រុក** | 4,076,991.0 | 733,578.9 | 17.99% | 122,859.5 | -63,447.8 | 105,290.0 | 313,051.6 | 103,623.8 | 152,201.9 | ... | ... | ... | ... | ... | ... |
| 3324 | កម្ចី | 4,076,991.0 | 733,578.9 | 17.99% | 122,859.5 | -63,447.8 | 105,290.0 | 313,051.6 | 103,623.8 | 152,201.9 | ... | ... | ... | ... | ... | ... |

# តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

## ២.៥.តារាងស្ថិតិស្តីពីភាពខុសគ្នារវាងស្ថិតិ TOFE និងស្ថិតិ GFS

| តារាងស្ថិតិពីភាពខុសគ្នារវាងស្ថិតិ TOFE និងស្ថិតិ GFS | ច្បាប់ឆ្នាំ ២០២០ | អនុវត្តន៍ ២០២០ | អនុ/ច្ប ២០២០ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ***ស្ថិតិ TOFE÷ ចំណូលក្នុងប្រទេស*** | **24,092,665** | **11,126,853** | **46.18%** | **1,685,856** | **1,883,057** | **1,975,153** | **2,655,375** | **1,481,927** | **1,445,484** | **-** | **-** | **-** | **-** | **-** | **-** |
| *បូក÷* | *-* | *488,488* | *-* | *79,856* | *79,856* | *79,856* | *89,206* | *79,856* | *79,856* | *-* | *-* | *-* | *-* | *-* | *-* |
| អំណោយ-ទ្រទ្រង់ថវិកា | *162,000* | *9,349* | - | - | - | - | *9,349* | - | - | - | - | - | - | - | - |
| អំណោយ | *958,277* | *479,139* | - | *79,856* | *79,856* | *79,856* | *79,856* | *79,856* | *79,856* | - | - | - | - | - | - |
| *ដក÷* | *-* | *143,795* | *-* | *3,431* | *17,387* | *20,158* | *59,670* | *17,184* | *25,966* | *-* | *-* | *-* | *-* | *-* | *-* |
| ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ | *150,000* | *69,079* | - | *2,956* | *12,029* | *3,013* | *15,655* | *14,105* | *21,321* | - | - | - | - | - | - |
| ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | - | *1,749* | - | - | *1,626* | - | *123* | - | - | - | - | - | - | - | - |
| ផលហិរញ្ញវត្ថុផ្សេងទៀត | - | *1,939* | - | *474* | *371* | *312* | *223* | *389* | *169* | - | - | - | - | - | - |
| ការឲ្យខ្ចី (ការសងវិញនូវមូលធន) | *193,341* | *71,028* | - | - | *3,361* | *16,833* | *43,669* | *2,689* | *4,476* | - | - | - | - | - | - |
| **ស្ថិតិ GFS÷ ចំណូល** | **24,869,592** | **11,471,546** | **46.13%** | **1,762,282** | **1,945,526** | **2,034,852** | **2,684,912** | **1,544,600** | **1,499,374** | **...** | **...** | **...** | **...** | **...** | **...** |
| | | | | | | | | | | | | | | | |
| ***ស្ថិតិ TOFE÷ ចំណាយសរុប*** | **29,989,933** | **11,149,099** | **37.18%** | **1,093,655** | **1,961,000** | **2,101,826** | **2,015,874** | **1,397,051** | **2,579,693** | **-** | **-** | **-** | **-** | **-** | **-** |
| *បូក÷* | *-* | *(3,688)* | *-* | *(474)* | *(1,997)* | *(312)* | *(346)* | *(389)* | *(169)* | *-* | *-* | *-* | *-* | *-* | *-* |
| ផលហិរញ្ញវត្ថុផ្សេងទៀត | - | *(1,939)* | - | *(474)* | *(371)* | *(312)* | *(223)* | *(389)* | *(169)* | - | - | - | - | - | - |
| ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | - | *(1,749)* | - | - | *(1,626)* | - | *(123)* | - | - | - | - | - | - | - | - |
| *ដក÷* | *-* | *85,539* | *-* | *2,956* | *12,029* | *3,013* | *15,655* | *14,105* | *37,781* | *-* | *-* | *-* | *-* | *-* | *-* |
| ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ | *150,000* | *69,079* | - | *2,956* | *12,029* | *3,013* | *15,655* | *14,105* | *21,321* | - | - | - | - | - | - |
| **ស្ថិតិ GFS÷ ចំណាយសរុប** | **28,701,740** | **11,059,872** | **38.53%** | **1,090,224** | **1,946,974** | **2,098,502** | **1,999,873** | **1,382,556** | **2,541,743** | **...** | **...** | **...** | **...** | **...** | **...** |
| | | | | | | | | | | | | | | | |
| ***ស្ថិតិ TOFE÷ តុល្យភាពសរុប ឱនភាព/អតិរេក (I-II)*** | **(5,897,268)** | **(22,246)** | **...** | **592,201** | **(77,943)** | **(126,673)** | **639,502** | **84,876** | **(1,134,209)** | **-** | **-** | **-** | **-** | **-** | **-** |
| *បូក៖* | *-* | *488,488* | *-* | *79,856* | *79,856* | *79,856* | *89,206* | *79,856* | *79,856* | *-* | *-* | *-* | *-* | *-* | *-* |
| អំណោយ-ទ្រទ្រង់ថវិកា | *162,000* | *9,349* | - | - | - | - | *9,349* | - | - | - | - | - | - | - | - |
| អំណោយ | *958,277* | *479,139* | - | *79,856* | *79,856* | *79,856* | *79,856* | *79,856* | *79,856* | - | - | - | - | - | - |
| *ដក÷* | *-* | *54,568* | | *-* | *3,361* | *16,833* | *43,669* | *2,689* | *(11,984)* | *-* | *-* | *-* | *-* | *-* | *-* |
| ២.ចំណាយមូលធន | *193,341* | *71,028* | - | - | *3,361* | *16,833* | *43,669* | *2,689* | *4,476* | - | - | - | - | - | - |
| **ស្ថិតិ GFS÷ សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី** | **(3,832,148)** | **411,674** | **...** | **672,057** | **(1,448)** | **(63,650)** | **685,039** | **162,044** | **(1,042,369)** | **...** | **...** | **...** | **...** | **...** | **...** |
| | | | | | | | | | | | | | | | |
| ***ស្ថិតិ TOFE÷ ហិរញ្ញប្បទានពីក្រៅប្រទេស*** | **5,197,268** | **1,222,067** | **23.51%** | **202,716** | **16,409** | **185,146** | **402,257** | **183,480** | **232,058** | **-** | **-** | **-** | **-** | **-** | **-** |
| *ដក÷* | *1,120,277* | *488,488* | *-* | *79,856* | *79,856* | *79,856* | *89,206* | *79,856* | *79,856* | *-* | *-* | *-* | *-* | *-* | *-* |
| អំណោយ-ទ្រទ្រង់ថវិកា | *162,000* | *9,349* | - | - | - | - | *9,349* | - | - | - | - | - | - | - | - |
| អំណោយ | *958,277* | *479,139* | - | *79,856* | *79,856* | *79,856* | *79,856* | *79,856* | *79,856* | - | - | - | - | - | - |
| **ស្ថិតិ GFS÷ បំណុលសុទ្ធ** | **4,076,991** | **733,579** | **17.99%** | **122,859** | **(63,448)** | **105,290** | **313,052** | **103,624** | **152,202** | **...** | **...** | **...** | **...** | **...** | **...** |

## តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

### ៣. ក្រាហ្វិក












# តារាងស្ថិតិរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

## ៣. ក្រាហ្វិក












# ៤.ខ្ទបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលទូទៅ (១)

ឯកតា÷ លានរៀល

## តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

| | | អនុវត្តន៍ ២០១៥ | អនុវត្តន៍ ២០១៦ | អនុវត្តន៍ ២០១៧ | អនុវត្តន៍ ឆ្នាំ២០១៨ | អនុវត្តន៍ ឆ្នាំ២០១៩ (២) | ច្បាប់ឆ្នាំ ២០២០ | អនុវត្តន៍ ឆ្នាំ២០២០ ឆមាសទី១ (២) |
|---|---|---|---|---|---|---|---|---|
| | វិធីសាស្រ្តគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **14,409,681.0** | **16,913,324.7** | **19,386,751.9** | **23,599,112.0** | **29,607,287.6** | **27,113,288.0** | **11,973,794.4** |
| 11 | ពន្ធ | 11,468,515.3 | 12,800,088.3 | 15,192,684.4 | 18,560,887.3 | 23,812,451.6 | 22,879,453.0 | 10,563,000.8 |
| 13 | អំណោយ | 2,057,063.0 | 2,644,306.4 | 2,449,035.7 | 2,132,905.2 | 2,365,254.5 | 1,250,277.0 | 184,748.4 |
| 14 | ចំណូលផ្សេងៗ | 1,513,623.9 | 2,102,769.0 | 2,487,431.3 | 2,905,319.5 | 3,429,581.5 | 2,983,558.0 | 1,226,045.1 |
| **2** | **ចំណាយ** | **9,183,370.5** | **10,983,010.4** | **13,335,238.8** | **14,827,812.0** | **17,939,608.4** | **17,695,220.8** | **7,161,249.6** |
| 21 | បន្ទុកបុគ្គលិក | 4,149,137.6 | 5,124,588.2 | 6,297,239.8 | 7,412,913.8 | 8,353,925.4 | 9,034,534.3 | 4,083,500.7 |
| 22 | ទំនិញ និងសេវាកម្ម | 2,841,264.8 | 3,120,399.0 | 3,650,346.4 | 4,092,508.7 | 4,981,706.3 | 4,543,732.5 | 1,108,118.8 |
| 24 | ការប្រាក់ | 222839.138 | 291394.9996 | 288,323.1 | 338,017.6 | 366,559.1 | 542,077.0 | 166,073.6 |
| 25 | ឧបត្ថម្ភកធន | 20700.16198 | 82080 | 225,055.2 | 10,484.7 | 616,400.0 | 11,000.0 | 205,000.0 |
| 26 | អំណោយ | 870,531.7 | 915,823.9 | 1,220,989.1 | 93,788.2 | 616,119.9 | 554,800.4 | 134,795.5 |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 1,122,171.7 | 1,195,515.0 | 1,376,074.8 | 1,540,132.0 | 1,689,793.2 | 1,833,525.6 | 855,078.2 |
| 28 | ចំណាយផ្សេងៗ | 586,246.6 | 887,048.2 | 1,019,610.0 | 1,339,967.1 | 1,315,104.5 | 1,175,551.0 | 608,682.6 |
| ***GOB*** | *តុល្យភាពប្រតិបត្តិការដុល* | **5,226,310.5** | **5,930,314.3** | **6,051,513.1** | **8,771,300.1** | **11,667,679.2** | **9,418,067.2** | **4,812,544.8** |
| ***NOB*** | *តុល្យភាពប្រតិបត្តិការសុទ្ធ* | **5,226,310.5** | **5,930,314.3** | **6,051,513.1** | **8,771,300.1** | **11,667,679.2** | **9,418,067.2** | **4,812,544.8** |
| **31** | **ប្រតិបត្តិការទ្រព្យមិនមែនហិរញ្ញវត្ថុ**<br>**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | 5,700,651.6 | 6,173,781.6 | 6,747,190.9 | 7,663,906.8 | 8,326,657.5 | 11,299,962.3 | 3,570,159.7 |
| 311 | ទ្រព្យអចល័ត | 5,688,350.2 | 6,149,369.2 | 6,742,609.7 | 7,526,576.9 | 8,261,693.8 | 12,656,302.6 | 3,567,839.1 |
| 314 | ទ្រព្យសកម្មគ្មានផលិតភាព | 12,301.4 | 24,412.4 | 4,581.3 | 137,329.9 | 64,963.7 | 18,619.5 | 2,320.6 |
| ***2M*** | *ចំណាយសរុប* | 15,513,543.3 | 17,790,631.0 | 20,824,829.2 | 22,491,718.8 | 26,266,265.9 | 28,995,183.1 | 10,731,409.3 |
| ***NLB*** | *សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី* | **-474,341.1** | **-243,467.3** | **-695,677.8** | **1,107,393.3** | **3,341,021.7** | **-3,256,854.9** | **1,242,385.1** |
| **32** | **ប្រតិបត្តិការទ្រព្យហិរញ្ញវត្ថុ និង បំណុល (ហិរញ្ញប្បទាន)**<br>**ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | 1,719,816.4 | 1,833,690.1 | 2,800,848.2 | 2,693,628.9 | 6,042,205.3 | 820,218.0 | 1,395,530.3 |
| 321 | ក្នុងប្រទេស | 1,883,927.1 | 1,626,246.3 | 2,939,690.7 | 2,693,628.9 | 6,042,205.3 | 820,218.0 | 1,395,530.3 |
| **33** | **បំណុលសុទ្ធ** | 2,194,086.0 | 2,077,158.8 | 1,750,968.1 | 1,610,591.5 | 2,758,181.5 | 4,076,991.0 | 154,894.0 |
| 331 | ក្នុងប្រទេស | 220,291.3 | 115,194.1 | -466,420.5 | -266,244.5 | 274,364.1 | ... | -578,684.9 |
| 332 | ក្រៅប្រទេស | 2137905.351 | 1754520.897 | 2,356,231.1 | 1,876,835.9 | 2,483,817.5 | 4,076,991.0 | 733,578.9 |

(១) មិនរួមបញ្ចូលទិន្នន័យគ្រឹះស្ថានសាធារណៈរដ្ឋបាល និងទិន្នន័យបេឡាជាតិរបបសន្តិសុខសង្គម

(២) ទិន្នន័យបឋម, ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០

# ៥.ឧបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ (១)

ឯកតា÷ លានរៀល

## តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

| | | អនុវត្តន៍ ២០១៥ | អនុវត្តន៍ ២០១៦ | អនុវត្តន៍ ២០១៧ | អនុវត្តន៍ ឆ្នាំ២០១៨ | អនុវត្តន៍ ឆ្នាំ២០១៩ (២) | ច្បាប់ឆ្នាំ ២០២០ | អនុវត្តន៍ ឆ្នាំ២០២០ ឆមាសទី១ (២) |
|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| 1 | ចំណូល | 1,449,977.4 | 1,444,774.2 | 1,796,172.6 | 2,863,180.4 | 3,909,121.2 | 3,329,964.0 | 1,649,591.5 |
| 11 | ពន្ធ | 761,372.3 | 755,258.1 | 1,009,595.3 | 1,586,513.4 | 2,104,418.9 | 2,086,308.0 | 779,268.9 |
| 13 | អំណោយ | 634,297.1 | 635,351.4 | 744,479.7 | 1,225,729.1 | 1,742,688.3 | 1,086,268.0 | 843,603.5 |
| 14 | ចំណូលផ្សេងៗ | 54,308.0 | 54,164.7 | 42,097.6 | 50,937.9 | 62,014.0 | 157,388.0 | 26,719.1 |
| 2 | ចំណាយ | 974,628.8 | 1,078,847.2 | 1,279,522.0 | 1,594,824.6 | 2,456,729.7 | 2,067,191.0 | 599,371.7 |
| 21 | បន្ទុកបុគ្គលិក | 225,075.1 | 308,999.5 | 343,718.4 | 418,454.6 | 500,918.1 | 736,168.1 | 258,944.9 |
| 22 | ទំនិញ និងសេវាកម្ម | 684,972.7 | 696,590.9 | 843,084.7 | 1,035,442.4 | 1,799,716.0 | 1,153,689.2 | 291,824.0 |
| 25 | ឧបត្ថម្ភធន | ... | ... | ... | ... | 4800 | ... | ... |
| 26 | អំណោយ | 42.1 | 42.9 | 37.4 | 9.8 | 7.6 | 68.0 | 0.0 |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 9,708.6 | 11,504.4 | 16,358.0 | 16,514.1 | 15,536.6 | 21,833.2 | 5,519.4 |
| 28 | ចំណាយផ្សេងៗ | 54,830.4 | 61,709.5 | 76,323.4 | 124,403.7 | 135,751.3 | 155,432.5 | 43,083.3 |
| GOB | *តុល្យភាពប្រតិបត្តិការដុល* | 475,348.6 | 365,927.1 | 516,650.6 | 1,268,355.8 | 1,452,391.5 | 1,262,773.0 | 1,050,219.8 |
| NOB | *តុល្យភាពប្រតិបត្តិការសុទ្ធ* | 475,348.6 | 365,927.1 | 516,650.6 | 1,268,355.8 | 1,452,391.5 | 1,262,773.0 | 1,050,219.8 |
| 31 | ប្រតិបត្តិការទ្រព្យមិនមែនហិរញ្ញវត្ថុ<br>ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ | 313,219.4 | 294,622.4 | 304,720.5 | 533,916.5 | 645,251.3 | 687,479.9 | 219,508.5 |
| 311 | ទ្រព្យអចលត៍ | 311,694.1 | 276,672.4 | 304,681.1 | 533,422.3 | 631,037.2 | 668,860.4 | 217,187.9 |
| 314 | ទ្រព្យសកម្មគ្មានផលិតភាព | 1,525.3 | 17,950.0 | 39.4 | 494.2 | 14,214.1 | 18,619.5 | 2,320.6 |
| 2M | *ចំណាយសរុប* | 1,287,848.2 | 1,373,469.6 | 1,584,242.6 | 2,128,741.1 | 3,101,981.0 | 2,754,670.9 | 818,880.2 |
| NLB | *សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី* | 162,129.2 | 71,304.7 | 211,930.1 | 734,439.3 | 807,140.2 | 575,293.1 | 830,711.3 |
| 32 | ប្រតិបត្តិការទ្រព្យហិរញ្ញវត្ថុ និង បំណុល (ហិរញ្ញប្បទាន)<br>ទ្រព្យហិរញ្ញវត្ថុសុទ្ធ | 271,748.2 | 52,119.5 | 333,478.0 | 848,034.8 | 1,201,410.0 | 575,375.0 | 252,026.3 |
| 321 | ក្នុងប្រទេស | 271,748.2 | 52,119.5 | 333,478.0 | 848,034.8 | 1,201,410.0 | 575,375.0 | 252,026.3 |
| 33 | បំណុលសុទ្ធ | 109,619.0 | -19,183.6 | 121,548.0 | 113,596.0 | 394,269.8 | ... | -578,684.9 |
| 331 | ក្នុងប្រទេស | 109,619.0 | -19,183.6 | 121,548.0 | 113,596.0 | 394,269.8 | ... | -578,684.9 |

(១) ស្ថិតិសមាសរវាងរដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ កម្រិត (រួមមានរដ្ឋបាលរាជធានី/ខេត្ត, រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ, និងរដ្ឋបាលឃុំ/សង្កាត់)

(២) ទិន្នន័យបឋម, ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០

## ៦.សេចក្តីសង្ខេបស្តីអំពី "ក្របខ័ណ្ឌប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល"

## អនុលោមទៅតាម Government Finance Statistics (GFSM2014)

### 1. របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

1.1. **របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល** ជារបាយការណ៍មួយដែលបង្ហាញយ៉ាងលម្អិតតាមរយៈប្រតិបត្តិការសំខាន់ៗ ដូចជា÷ ចំណូល, ចំណាយ, វិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ, វិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ, និងបំណុលសុទ្ធ។ ផ្អែកលើក្របខ័ណ្ឌស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលនេះ **ចំណូល** គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យសកម្ម (net worth) កើនឡើង។ រីឯ**ចំណាយ** គឺជាប្រតិបត្តិការ (transactions) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យសកម្មថយចុះ។ **ការវិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ** គឺជាលទ្ធផលនៃអចលនទ្រព្យ (fixed assets) បូកសន្និធិសុទ្ធ, ទ្រព្យមានតម្លៃសុទ្ធ និងទ្រព្យគ្មានផលិតភាពសុទ្ធ (non-produce assets) ។

1.2. នៅក្នុងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលមានតុល្យភាពចំនួន ០២ ដែលជាធាតុដ៏សំខាន់ក្នុងកិច្ចការវិភាគ។ តុល្យភាពទី១ គឺជាផលសងនៃចំណូល និងចំណាយ ដែលហៅថា **តុល្យភាពប្រតិបត្តិការសុទ្ធ** និងតុល្យភាពទី២ គឺជាផលសងនៃតុល្យភាពប្រតិបត្តិការសុទ្ធ និងការវិនិយោគលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ដែលហៅថា **តុល្យភាពការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ**។ តុល្យភាពទី២នេះ ក៏អាចបង្ហាញតាមរយៈផលសងនៃការវិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលសុទ្ធ។

1.3. **តុល្យភាពប្រតិបត្តិការសុទ្ធ** ទិន្នន័យតុល្យភាពនេះអាចយកទៅប្រៀបធៀបជាមួយគណនីជាតិតាមរយៈការបូកបញ្ចូលគ្នានៃការសន្សំនិងមូលនិធិផ្ទេរដែលត្រូវទទួល។ **តុល្យភាពប្រតិបត្តិការសុទ្ធ**នៅទីនេះមិនបានរាប់បញ្ចូលចំណេញ ឬខាតដែលកើតចេញពី ការប្រែប្រួលថ្លៃ (change in price level) និងការប្រែប្រួលជាបរិមាណ (other change in the volume)ទ្រព្យសកម្ម ឬបំណុលឡើយ។ គោលនយោបាយរបស់ រដ្ឋាភិបាលមានឥទ្ធិពលផ្ទាល់លើប្រតិបត្តិការដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យប្រែប្រួលព្រោះតែរដ្ឋាភិបាលជាអ្នកគ្រប់គ្រងដោយផ្ទាល់លើសេចក្តីសម្រេចចិត្តចំពោះគ្រប់ប្រតិបត្តិការទាំងអស់។ ចំណេញ ឬខាតចេញពីការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្ម ឬបំណុល(ប្រែប្រួលថ្លៃទីផ្សារ)និងការប្រែប្រួលជាបរិមាណ (ដោយសារព្រឹត្តិការណ៍ណាមួយ) គឺមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាលឡើយ តែរដ្ឋាភិបាលអាចមានយន្តការ ឬគោលនយោបាយដើម្បីកាត់បន្ថយផលប៉ះពាល់ដែលកើតចេញពីការប្រែប្រួលខាងលើឱ្យស្ថិតក្នុងកម្រិតអប្បបរមា។

1.4. **តុល្យភាពការឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធ** ដែលបង្ហាញឱ្យឃើញពីការប្រើប្រាស់ (វិនិយោគ) ធនធានហិរញ្ញវត្ថុទៅវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ការឱ្យខ្ចី) ឬបង្ហាញឱ្យឃើញពីការទាញយកអត្ថប្រយោជន៍ប្រភពហិរញ្ញប្បទាន

ពីវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ប្រាក់កម្ចី)។ តុល្យភាពនេះជាសូចនាករមួយដែលបង្ហាញឱ្យឃើញពីឥទ្ធិពលនៃសកម្មភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលទៅលើសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។

**1.5. តុល្យភាពប្រតិបត្តិការដុល÷** មានភាពខុសគ្នាពីតុល្យភាពប្រតិបត្តិការសុទ្ធនៅត្រង់ថាតុល្យភាពប្រតិបត្តិការដុលមិនបានរួមបញ្ចូលនូវចំណាយលើការប្រើប្រាស់(រំលោះ)ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុឡើយ។ ចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពលំបាកក្នុងការវាយតម្លៃ។ ប្រសិនបើតុល្យភាពប្រតិបត្តិការដុលធំជាងតុល្យភាពប្រតិបត្តិការសុទ្ធនេះមានន័យថាចំណាយលើការប្រើប្រាស់លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានកត់ត្រា។

**1.6. ចំណាយសរុប** (expenditure) គឺជាលទ្ធផលដែលបានមកពីចំណាយ (expenses) និងវិនិយោគ (ការទិញ/ដោះដូរ)លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ចំណាយសរុបនេះបានរួមបញ្ចូលទាំងចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពសមស្របសម្រាប់ការប្រៀបធៀបជាមួយបណ្តាប្រទេសផ្សេងៗ បើទោះបីជាការវាយតម្លៃចំណាយរំលោះនៅមិនទាន់មានសង្គតិភាពនៅឡើយក៏ដោយ។

**1.7. ចំណូល** គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកើនឡើង។ ធាតុសំខាន់ៗនៃចំណូលរួមមាន÷ ចំណូលពន្ធ (១១), ចំណូលពីការចូលរួមសង្គម (១២), ចំណូលពីអំណោយ (១៣), និងចំណូលផ្សេងៗ (១៤) ។ ចំណូលដែលបានមកពីការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលប្រើប្រាស់រួច (ជម្រះបញ្ជី) មិនត្រូវបានទទួលស្គាល់ជាចំណូលឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្មនោះទេ។ អ្វីដែលប្រែប្រួលចេញពីប្រតិបត្តិការនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ ពោលគឺទ្រព្យសកម្មមួយថយចុះ (ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ)ហើយ ទ្រព្យសកម្មផ្សេងកើនឡើង (សាច់ប្រាក់)។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលទទួលបានឬការសងបំណុលដែលគេជំពាក់ ក៏មិនត្រូវបានចាត់ទុកជាចំណូលដែរ។

**1.8. ចំណាយ** គឺជាប្រតិបត្តិការ (transaction)ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យថយចុះ។ ធាតុសំខាន់ៗនៃចំណាយ រួមមាន÷ ចំណាយប្រាក់បៀវត្ស និងលាភការ (២១), ចំណាយការប្រើប្រាស់ទំនិញ និងសេវាកម្ម (២២), ចំណាយលើការប្រាក់ (២៤) ,ចំណាយលើការឧបត្ថម្ភធន (២៥), ចំណាយលើអំណោយ (២៦) ចំណាយលើឧបត្ថម្ភសង្គមកិច្ច (២៧), និងចំណាយផ្សេងៗ(២៨)។ មិនត្រឹមតែប៉ុណ្ណោះ ចំណាយក៏ត្រូវបានធ្វើចំណាត់ថ្នាក់ ទៅតាមមុខងាររបស់រដ្ឋាភិបាលផងដែរ ដូចជា÷ ចំណាយលើសុខភាព ឬកិច្ចការពារសង្គមជាដើម។ ការទិញ ឬដោះដូរទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ មិនត្រូវបានចាត់ទុកជាចំណាយឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យឡើយ។ ការប្រែប្រួលកើតចេញពីប្រតិបត្តិការខាងលើនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលបានសង ក៏មិនត្រូវបានចាត់ទុកជាចំណាយដែរ។

**1.9.** ផ្នែកទីពាំនៃរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលនេះ គឺជា**ប្រតិបត្តិការហិរញ្ញវត្ថុ** ទាំងឡាយដែលធ្វើឱ្យមានបម្រែបម្រួលទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល។ ប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើដៃគូ (counterpart) ដែលបានជំពាក់ (ទាំងក្នុង និងក្រៅប្រទេស) ទាំងក្នុងទ្រព្យសកម្ម និងបំណុល។

1.10. បន្ថែមលើចំណាត់ថ្នាក់ខាងលើ ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលមានដូចជា៖ រូបិយវត្ថុ មាស និងអេសឌីអា, រូបិយប័ណ្ណ និងប្រាក់បញ្ញើ, មូលបត្របំណុល, កម្ចី, ដើមទុន និងមូលនិធិភាគហ៊ុន, ធានារ៉ាប់រង សោធន និងកញ្ចប់ធានារ៉ាប់រង, ដេរីវេទីវហិរញ្ញវត្ថុ និងភាគហ៊ុនបុគ្គលិក, គណនីត្រូវទទួល/ត្រូវសងផ្សេងៗ។ មិនត្រឹមតែប៉ុណ្ណោះប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើវិស័យដែលជាដៃគូបដិភាគនៃឧបករណ៍ហិរញ្ញវត្ថុដូចជា៖ សាជីវកម្មហិរញ្ញវត្ថុ, សាជីវកម្មមិនមែនហិរញ្ញវត្ថុ, គេហកិច្ច (household) និងស្ថាប័នមិនស្វែងរកប្រាក់ចំណេញ។

**1.11.** មធ្យោបាយម្យ៉ាងទៀត នៃការធ្វើចំណាត់ថ្នាក់ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល គឺដោយផ្អែកលើការកើនឡើងថ្មី ឬក៏ការជម្រះចេញ ដែលបម្រើឱ្យគោលដៅនយោបាយ ឬក៏ផ្អែកលើការគ្រប់គ្រងសន្ទនីភាព។ ភាពខុសគ្នានោះនៅត្រង់ថាវាមិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលទេ តែវាត្រូវប្រើសម្រាប់កំណត់តុល្យភាពសារពើពន្ធ។

**1.12.** គោលនយោបាយសាធារណៈដែលទាក់ទងទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលអាចត្រូវបានលើកមកគិតគូរក្នុងហេតុផលផ្សេងៗ ដូចជាការជម្រុញឧស្សាហកម្មថ្មី, ជួយសង្គ្រោះសាជីវកម្មសាធារណៈ, ឬក៏ជួយអាជីកម្មណាមួយដើម្បីឱ្យមានភាពសម្បូរបែបក្នុងសេដ្ឋកិច្ច។ ប្រតិបត្តិការទាំងនេះអាចមានទម្រង់ផ្សេងៗគ្នាដូចជា៖ កម្ចី, មូលបត្រដើមទុន ឬមូលបត្របំណុលជាដើម។ ជាមួយគ្នានេះដែរ ប្រតិបត្តិការខាងលើក៏អាចមានផងដែរក្នុងទម្រង់ជាសម្បទាន។

**1.13.** ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទៀត គឺត្រូវបានសន្មត់ថាជាការគ្រប់គ្រងសន្ទនីភាពឬក៏គោលបំណងផ្សេង។ ដែលនេះបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រងដោយបានទាញយកផលប្រយោជន៍ស្របតាមអត្រាទីផ្សារ ព្រមទាំងធានាបាននូវមូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ ឬគ្រប់គ្រាន់ជាមួយតម្រូវការសង្គមនៅពេលខាងមុខដូចជាមូលនិធិពិសេសរបស់រដ្ឋាភិបាលជាដើម។

# ចំណាំ

## តារាងស្ថិតិឆ្នាំ ២០២០

**វិធីសាស្ត្រស្ថិតិ គោលការណ៍ណែនាំឆ្នាំ២០១៤ ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល**

**ឯកតា : លានរៀល**

**វិសាលភាពស្ថាប័ន : រដ្ឋាភិបាលទូទៅ (មិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល និងបេឡាជាតិរបបសន្តិសុខសង្គម)**

កម្រិតរដ្ឋាភិបាល÷ រដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល (ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២០)

កម្រិតរដ្ឋាភិបាល÷ រដ្ឋាភិបាលទូទៅ (ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២០)

កម្រិតរដ្ឋាភិបាល÷ រដ្ឋបាលថ្នាក់ក្រោមជាតិ (ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២០)

**Reference:** *Government Finance Statistics Manual 2014 (GFSM 2014)*